ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌ

លេខ ២៧៨

ចុះថ្ងៃទី១៣-០២-២០០៧

សាលក្រមលេខ ៤៨ "ឥ"

ចុះថ្ងៃទី០៨-៧-២០០៩

**<u>តាងនាមប្រជារាស្ត្រខ្មែរ</u>**

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០៩

ដោយមានសមាសភាពដូចរូបមន្តតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**

-លោកស្រី [redacted] អនុប្រធាន សាលាដំបូងរាជធានីភ្នំពេញ

**<u>តំណាងអយ្យការ</u>**

-លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៧៧ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលមានជនជាប់ចោទ :

-ឈ្មោ[redacted] ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអណ្តូង ផ្លូវលំ ឃុំគោករកា ស្រុកដង្កោ ខេត្តកណ្តាល ទីលំនៅពេលចាប់ខ្លួននៅភូមិអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរ ពាណិជ្ជករ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោ[redacted] " ប្រពន្ធឈ្មោ[redacted] " កូនគ្មាន ទោសពីមុនមាន ។

ត្រូវឃាត់ខ្លួននៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ឃុំខ្លួននៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ។

-ត្រូវចោទពីបទ ផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៤ .កាលពីថ្ងៃទី ០៩ ខែ១២ ឆ្នាំ១៩៩៣ .កាលពីថ្ងៃទី ៣១ ខែ១២ ឆ្នាំ១៩៩៣ តាមបញ្ញត្តិមាត្រា ៥៦ .៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-មេធាវីការពារជនជាប់ចោទលោក[redacted]

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]អាយុ៥៣ឆ្នាំ.មានទីលំនៅបច្ចុប្បន្នផ្ទះលេខ២៤៥ ផ្លូវ១០១៩ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលមានលោក [redacted]ជាមេធាវីតំណាង ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u> :

កាលពីថ្ងៃទី ០៩-១២-១៩៩៣ .ថ្ងៃទី៣១-១២-១៩៩៣ និងថ្ងៃទី០៤-១០-២០០៤ ឈ្មោះ [redacted]បាន ធ្វើសកម្មភាពជាមួយគូកន ក្លែងលិខិតឯកជន និងផ្តល់សក្ខីភាពក្លែង ក្នុងគោលបំណងបន្លំឈ្មោះ ស្នាមមេដៃ របស់ឈ្មោះ[redacted]ដើម្បីរំលោភយកដីនៅចំណុចភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ពីម្ចាស់កម្មសិទ្ធដីខាងលើ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៦៧០ អ.យ.ជ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៧២៧៥ តព្រ ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted]បានឆ្លើយថា : កាលពីថ្ងៃទី០៩-១២-១៩៩៣ ខ្លួនបានទិញដីទំហំ ៤៧៨៥ ម៉ែតការ៉េ ដែលមានទីតាំងស្ថិតនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ក្នុងតំលៃ 0.៥០$/m²



Scanned by CamScanner

ពីឈ្មោះ [redacted] ដោយខ្លួនឱ្យឈ្មោះ [redacted] ជាអ្នករៀបចំឯកសារក្នុងការទិញលក់ទាំងនោះ ខ្លួនមិនបានធ្វើការទិញផ្ទាល់ដោយខ្លួនឯងទេ។ រាល់លិខិតទិញលក់ទាំងអស់គឺខ្លួនឱ្យឈ្មោះ [redacted] ជាអ្នកធ្វើ ហើយខ្លួនចាំតែផ្តិតមេដៃតែប៉ុណ្ណោះ ការផ្តិតមេដៃនោះគឺខ្លួនមិនបានផ្តិតមេដៃនៅចំពោះមុខ [redacted] ចំណែកឯលិខិតប្រគល់ប្រាក់ផ្តាច់ ចុះថ្ងៃទី៣១-១២-១៩៩៣ គឺឈ្មោះ [redacted] នយកឯកសារនេះឱ្យខ្លួនផ្តិតមេដៃ ហើយខ្លួនបានប្រគល់លុយតាមរយៈឈ្មោះ [redacted] ។បានជាខ្លួនទុកចិត្តលើឈ្មោះ [redacted] ដោយឈ្មោះ [redacted] នេះគាត់ជាប្រធានប៉ុស្តិ៍នគរបាលសង្កាត់ភ្នំពេញថ្មី។ ខ្លួនមិនដែលបានស្គាល់មុខឈ្មោះ [redacted] ទេ ហើយក្នុងទំនាក់ទំនងទិញលក់ដីនេះគឺតាមរយៈឈ្មោះ [redacted] ទាំងអស់ ចំពោះលិខិត ចុះថ្ងៃទី០៩-១២-១៩៩៣ និងលិខិត ចុះថ្ងៃទី៣១-១២-១៩៩៣ ក្លែងរឺមិនក្លែងខ្លួនមិនដឹងទេ។ ឈ្មោះ [redacted] សព្វថ្ងៃនេះបានស្លាប់បាត់ហើយ ចំពោះកំហេតុហេតុសួរចម្លើយឈ្មោះ [redacted] នៅតុលាការ ខ្លួនពុំបានដឹងទេគឺតុលាការគេចាត់ការទៅតាមនីតិវិធីគេតែប៉ុណ្ណោះ។

-តាមអំណោនចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា: បណ្តឹងដែលខ្លួនបានប្តឹងលើឈ្មោះ [redacted] បទ ផ្តល់សក្ខីភាពក្លែង និងលិខិតកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី០៩-១២-១៩៩៣ និងលិខិតប្រគល់ប្រាក់ ចុះថ្ងៃទី៣១-១២-១៩៩៣ ចូលមកលោកព្រះរាជអាជ្ញា កាលពីថ្ងៃទី១៣-០២-២០០៧ ខ្លួនសុំរក្សាខ្លឹមសារក្នុងបណ្តឹងទាំងស្រុង។ ចំពោះកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី០៩-១២-១៩៩៣ រវាងឈ្មោះ [redacted] ងឈ្មោះ [redacted] និងលិខិតប្រគល់ប្រាក់ផ្តាច់ ចុះថ្ងៃទី៣១-១២-១៩៩៣ រវាងឈ្មោះ [redacted] និងឈ្មោះ [redacted] ដែរនោះ ខ្លួនសុំបដិសេធចោលព្រោះខ្លួនពុំដែលបានចុះកិច្ចសន្យា ឬផ្តិតមេដៃលើលិខិតទាំងនោះឡើយ។ ម្យ៉ាងទៀតខ្លួនពុំដែលស្គាល់ឈ្មោះ [redacted] នេះទេ ។ ឯកំណត់ហេតុសួរចម្លើយឈ្មោះ [redacted] ចុះថ្ងៃទី២៩-៤-២០០៤ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ២២៨ ចុះថ្ងៃទី០២-៣-២០០៤ ដែលមានឈ្មោះ [redacted] ជាចៅក្រម លោក [redacted] ក្រឡាបញ្ជី ខ្លួនពុំដែលបានចូលមកឆ្លើយចំពោះមុខគាត់ឡើយ។ កំណត់ហេតុនេះប្រឌិតខុសពីការពិតទាំងស្រុង ព្រោះខ្លួនពុំដែលតុលាការកោះអញ្ជើញម្តងណាឡើយ។ ចំពោះរឿងនេះខ្លួនសំណូមពរដូចមានក្នុងពាក្យបណ្តឹង។

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានថា : ឆ្លងតាមអង្គសវនាការឃើញថាទោះបីជនជាប់ចោទឈ្មោះ [redacted] បានសារភាពថា ខ្លួនពិតជាបានផ្តល់សក្ខីភាពក្លែងប្រាកដមែន ដោយធ្វើតែម្នាក់ឯងគ្មានអ្នកណាចូលរួមទេ ក៏ប៉ុន្តែបើពិនិត្យទៅលើឯកសារដែលតុលាការទទួលបានវិញ ឃើញថាឈ្មោះ [redacted] ពិតជាបានផ្តល់សក្ខីភាពក្លែងដែលមានតួនាទីក្នុងការប្រព្រឹត្តតាំងពីដើមរហូតដល់ចប់។

ដូចនេះក្នុងនាមខ្លួនតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ និងទាមទារជំងឺចិត្ត ៥០.០០០ ដុល្លារអាមេរិក (ប្រាំម៉ឺនដុល្លារអាមេរិក) ព្រមទាំងស្នើសុំឱ្យតុលាការស្រាវជ្រាវរកជនដែលពាក់ព័ន្ធធ្វើការបន្លំស្នាមមេដៃទៅលើដើមបណ្តឹងឈ្មោះ [redacted]

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ : ឆ្លងតាមអង្គសវនាការឃើញថាទោះបីជនជាប់ចោទឈ្មោះ [redacted] ពុំបានឆ្លើយសារភាពដោយស្មោះត្រង់ក៏ដោយ តែតាមឯកសារដែលតុលាការទទួលបានបញ្ជាក់ឱ្យឃើញថា: ឈ្មោះ [redacted] ប្រព្រឹត្តកន្លងមកមានតួនាទីមិនអាចធ្វើតែម្នាក់ឯងកើតនោះទេ។

សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនៅតែចោទប្រកាន់លើឈ្មោះ [redacted] ពីបទ ផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៤ .កាលពីថ្ងៃទី ០៩ ខែ១២ ឆ្នាំ១៩៩៣ .កាលពីថ្ងៃទី ៣១ ខែ១២ ឆ្នាំ១៩៩៣ ដោយឡែកតួនាទីដែលពាក់ព័ន្ធសុំឱ្យ តុលាការបំបែកសំណុំរឿងដើម្បីស្រាវជ្រាវយកមកចោទប្រកាន់សំរេចផ្តន្ទាទោសទៅតាមច្បាប់។

មេធាវីជនជាប់ចោទសន្និដ្ឋានការពារ: ខ្ញុំយល់ថាកូនក្តីខ្ញុំធ្វើតាមគេជាអ្នកធ្វើឱ្យដោយឈ្មោះ [redacted] ជាអ្នកធ្វើឱ្យ តែកូនក្តីខ្ញុំដោយរៀនបានតិចវប្បធម៌តិចពេកក៏មិនបានពិចារណាវែងឆ្ងាយទើបគាត់ធ្វើដូចនេះ សូមលោកស្រីចៅក្រមជំនុំជំរះ មេត្តាជួយបន្ធូរបន្ថយទោសឱ្យកូនក្តីខ្ញុំបានដោយក្តីអនុគ្រោះ។

-ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹង



Scanned by CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យឯកសារតាង
-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**ឃើញថាៈ**

-កាលពីថ្ងៃទី ០៩-១២-១៩៩៣ ,ថ្ងៃទី៣១-១២-១៩៩៣ ថ្ងៃទី១៩-៥-២០០៤ និងថ្ងៃទី០៤-១០-២០០៤ តាមសាលក្រមលេខ ១៤"ឈ" មានអំពើផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជនមួយកើតឡើងនៅក្រុងភ្នំពេញ ដែលអំពើនេះបង្កឡើងដោយឈ្មោ[redacted]

-តាមចម្លើយរបស់ឈ្មោះ[redacted]ដើមបណ្តឹងបានឆ្លើយថាៈ ចំពោះកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ០៩ ខែ១២ ឆ្នាំ១៩៩៣ និងលិខិតប្រគល់ប្រគល់ប្រាក់ផ្តាច់ ចុះថ្ងៃទី៣១-១២-១៩៩៣ រវាងឈ្មោះ [redacted]និងឈ្មោះ [redacted]ខ្លួនពុំបានចុះកិច្ចសន្យា ឬផ្តិតមេដៃលើលិខិតទាំងនោះឡើយ ។

-ឈ្មោះ[redacted]បានឆ្លើយថាៈ ខ្លួនពុំស្គាល់ឈ្មោ[redacted]ទេ ហើយក៏ពុំដែលបានចូលមកឆ្លើយចំពោះមុខលោកចៅក្រម[redacted]ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ២២៨ ចុះថ្ងៃទី០២-៣-២០០៤ នោះដែរ ។

-តាមកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី០៩-១២-១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្តាច់ ចុះថ្ងៃទី៣១-១២-១៩៩៣ បានបង្ហាញថាឈ្មោ[redacted]គឺជាអ្នកលក់ដី និងទទួលប្រាក់ ប៉ុន្តែការបំភ្លឺរបស់ដើមបណ្តឹងឈ្មោ[redacted] បញ្ជាក់ថាខ្លួនមិនដែលផ្តិតមេដៃលក់ដី និងទទួលប្រាក់ពីឈ្មោ[redacted]ឡើយ នេះបញ្ជាក់ថា លិខិតស្នាមដែល[redacted] ធ្វើឡើងនេះគឺជាឯកសារក្លែងក្លាយទាំងអស់ ។

-ការផ្តល់ភស្តុតាងរបស់ជនជាប់ចោទឈ្មោះ[redacted]នូវឈ្មោះ[redacted]ក្នុងកំណត់ហេតុយកចម្លើយ [redacted]ងសំណុំរឿងរដ្ឋប្បវេណីលេខ ២២៨ ចុះថ្ងៃទី០២-៣-២០០៤ បានឆ្លើយបញ្ជាក់ជូនតុលាការថា ខ្លួនមានដីទំហំ ២ហិចតា ស្ថិតក្នុងភូមិប៉ាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ដែលដីនេះខ្លួនបានលក់ឱ្យឈ្មោ[redacted]តំលៃ 0.៥$/m² ដែលជាហេតុធ្វើឱ្យតុលាការមានការភាន់ច្រឡំដល់ការសំរេចសេចក្តី ដើម្បីផ្តល់ចំលើយឱ្យតុលាការឱ្យមានការជឿជាក់ហើយមានការភាន់ច្រឡំ ក្នុងការសំរេចសេចក្តីដូចក្នុងសាលក្រមលេខ ១៤"ឈ" ចុះថ្ងៃទី ១៩ ខែ០៥ ឆ្នាំ២០០៤ ហើយបានបញ្ជាក់សាលក្រម ចូលស្ថាពរ ចុះថ្ងៃទី ០៤ ខែ១០ ឆ្នាំ២០០៤ ។

-អំពើរបស់ជនជាប់ចោទឈ្មោះ[redacted]គឺជាការបង្ហាញនូវសក្ខីភាពក្លែងក្លាយក្នុងនីតិវិធីតុលាការ ហើយអំពើនេះជាបទធ្វើសក្ខីភាពក្លែងក្លាយតាមមាត្រា ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ[redacted]ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ជាសមត្ថជន មានសមត្ថភាពគ្រប់គ្រាន់ទទួលខុសត្រូវចំពោះមុខច្បាប់ ។

-តាមលទ្ធផលកោសល្យវិច័យរបស់ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រលេខ ១០កវ/២០០៦ ចុះថ្ងៃទី ២៦ ខែ១២ ឆ្នាំ២០០៦ ថាស្នាមមេដៃមានដាក់ឈ្មោះ [redacted]លើកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី ១០ ខែ១១ ឆ្នាំ២០០៦ ជាមួយនឹងស្នាមម្រាមដៃមានដាក់ឈ្មោ[redacted]លើកំនត់ហេតុយកចម្លើយ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៤ គឺមិនមែនជាស្នាមមេដៃតែមួយ នេះបញ្ជាក់ថាស្នាមមេដៃដែលផ្តិតលើកំណត់ហេតុថ្ងៃទី២៩-០៤-២០០៤ គឺជាមនុស្សក្លែងក្លាយ ។

-តាមការប្រកាសលទ្ធផលប្រៀបធៀបរបស់ការិយាល័យនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ លេខ ០២កវ/២០០៧ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៧ ថាស្នាមម្រាមដៃរបស់ឈ្មោះ [redacted]ដែលបានផ្តិតនៅលើកំនត់ហេតុសួរចម្លើយរបស់តុលាការក្រុងភ្នំពេញ ចុះថ្ងៃ ១០ ខែវិច្ឆិកា ឆ្នាំ២០០៦ ជាមួយស្នាមម្រាមដៃរបស់ឈ្មោ[redacted]ដែលបានស្កេនចេញពីអត្តសញ្ញាណប័ណ្ណលេខ 10221114 គឺជាស្នាមមេដៃរបស់មនុស្សតែម្នាក់[redacted]ពិតប្រាកដ ។

-ដើម្បីចៀសវាងការឃុំខ្លួនហួសនីតិវិធី តុលាការគប្បីផ្តន្ទាទោសជនជាប់ចោទនាពេលនេះ ឯអ្នកនតុលាការគប្បីបង្វិលសំណុំរឿងជូនលោកព្រះរាជអាជ្ញាវិញ ដើម្បីធ្វើការចោទប្រកាន់ និងចាត់ការតាមនីតិវិធីជាបន្តទៀត ។



Scanned by CamScanner

-តាមការផ្តល់ភស្តុតាង និងការអះអាងរបស់មេធាវីតំណាងដើមបណ្តឹងបញ្ជាក់ថា ចុងចោទមានសាវតាច្បាស់លាស់ ហើយចុងចោទនេះជាអ្នករៀបចំឯកសារក្លែង ហើយជាអ្នកផ្តល់ឯកសារប័ណ្ណកម្មសិទ្ធិថតចំលងផងដែរ ដែលការអះអាងនេះអាចឱ្យតុលាការជឿបាន ព្រោះថាជនជាប់ចោទពុំបានឆ្លើយបញ្ជាក់ជូនតុលាការនាពេលសវនាការថាអ្នកណាជាអ្នកផ្តល់ប័ណ្ណសិទ្ធិឱ្យមកខ្លួនបានឡើយ ដែលនេះសបញ្ជាក់ថាអ្នកផ្តល់ប័ណ្ណកម្មសិទ្ធិដើម្បីឱ្យតុលាការសំរេចបដិសេធនោះគឺជាចុងចោទ ហើយចុងចោទនេះតំណាងអយ្យការនៅពុំបានធ្វើការចោទប្រកាន់ និងបញ្ជូនមកតុលាការជំនុំជំរះឡើយ ដូចនេះដើម្បីកុំឱ្យជនប្រព្រឹត្តបទល្មើសរួចផុតពីការផ្តន្ទាទោស តុលាការគប្បីបង្វិលសំណុំរឿងទៅអយ្យការវិញ ដើម្បីធ្វើការចោទប្រកាន់លើចុងចោទ និងចាត់ការតាមនីតិវិធីជាបន្តទៀត ។

-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ ពីបទ ផ្តល់សក្ខីភាពក្លែង ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៩-៤-២០០៤,ថ្ងៃទី[redacted]-២០០៤ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់ ពីបទ ក្លែងលិខិតឯកជន កាលពីថ្ងៃទី០៩-១២-១៩៩៣ និងថ្ងៃទី៣១-១២-១៩៩៣ បទល្មើសដែលមានចែងឱ្យ ផ្តន្ទាទោសតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-លោកមេធាវី [redacted] មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នប្តឹងសុំទាមទារថ្លៃខូចខាត និងជំងឺចិត្តចំនួន ៥០.០០០ដុល្លា (ប្រាំម៉ឺនដុល្លាអាមេរិក) មានលក្ខណៈសមស្របគប្បីតុលាការពិនិត្យ និងសំរេចតាមភាពជាក់ស្តែង ។

## ហេតុដូច្នេះសំរេច

១-ផ្តន្ទាទោស: ឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអណ្តូង ផ្ទះលំ ឃុំគោករការ ស្រុកដង្កោ ខេត្តកណ្តាល ទីលំនៅពេលចាប់ខ្លួននៅភូមិអណ្តូង សង្កាត់គោករការ ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរពាណិជ្ជករ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] រ៍ កូនគ្មាន ទោសពីមុនមាន ។

ដាក់ពន្ធនាគារសរុបកំណត់ ០៤ឆ្នាំ (បួនឆ្នាំ) គិតបន្តពីសាលក្រមមុន និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០រៀល (បួនលានរៀល) សំរាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទ ផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៩-៤-២០០៤ ,ថ្ងៃទី១៩-៥-២០០៤, ថ្ងៃទី០៩-១២-១៩៩៣ និងថ្ងៃទី៣១-១២-១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥៦,៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់ឱ្យឈ្មោះ [redacted] សងថ្លៃការខូចខាត និងជំងឺចិត្តចំនួន ៤០.០០០.០០០រៀល(សែសិបលានរៀល) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ដែលមានលោកមេធាវី [redacted] ជាតំណាង ។ សុំលើសពីនេះត្រូវច្រានចោល ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ២៧៨ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ទៅព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបើកការស៊ើបសួរលើចុងចោទ និងចាត់ការតាមនីតិវិធី ។

៤-សាលក្រមនេះជំនុំជំរះជាសាធារណៈ ថ្ងៃទី២៤-៦-២០០៩ និងប្រកាសជាសាធារណៈ ថ្ងៃទី០៨-៧-២០០៩ ចំពោះមុខជនជាប់ចោទ [redacted] មេធាវីការពារជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា: [redacted]

ចៅក្រមជំនុំជំរះ

ហត្ថលេខា និងត្រា: [redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ខែកក្កដា ឆ្នាំ២០០៩

ក្រឡាបញ្ជី

ចៅក្រមជំនុំជំរះ



[redacted]

Scanned by CamScanner